

# ថ្ងៃអាទិត្យ

All Children Reading - Cambodia

Seng Visoth

letsreadasia.org



រៀងរាល់ព្រឹក ខ្ញុំតែងហាត់ប្រាណដើម្បី
ឱ្យមានសុខភាពល្អ។



ខ្ញុំងូតទឹក ហើយដុសធ្មេញ។



ខ្ញុំញ៉ាំអាហារពេលព្រឹក។



ខ្ញុំជួយមើលប្អូនស្រី។



ខ្ញុំឮសំឡេង «ក្រុកៗ»។



អូ! មាន់ឃ្លានហើយ។ ខ្ញុំត្រូវឱ្យចំណី
ពួកវាសិន។



មើលចុះ! ជ្រូកក៏ឃ្លានដែរ។ «អ៊ូក អ៊ូក អ៊ូក!»



អា! ដល់ពេលខ្ញុំលេងម្តងហើយ។



ថ្ងៃអាទិត្យ ការណែនាំបន្ថែមអំពី
ការប្រើប្រាស់សៀវភៅ សៀវភៅរឿង
នេះ បានផលិតឡើងដោយមានភ្ជាប់
នូវសកម្មភាពនៅក្នុងទំព័រនីមួយ
ៗ សម្រាប់ឱ្យសិស្សធ្វើសកម្មភាព
តាមសាច់រឿង។ នៅក្នុងសកម្មភាព
ទាំងនោះមានប្រើនូវញាណទាំ៥ និង
ចលនាផងដែរ។ លោកគ្រូអ្នកគ្រូអាច
អានរឿង បន្ទាប់មកសិស្សប្តូរវេនគ្នា
ដើម្បីធ្វើសកម្មភាព។ អត្ថបទរឿង
- រៀងរាល់ព្រឹក ខ្ញុំតែងហាត់ប្រាណ
ដើម្បីឱ្យមានសុខភាពល្អ។ សកម្មភាព
- គ្រូឱ្យសិស្សធ្វើចលនា លើកដៃ
ឡើងលើ ពត់ខ្លួនទៅឆ្វេង ពត់ខ្លួនទៅ



ស្អា សម្ភារៈដែលត្រូវប្រើ - គ្មាន អត្ថបទ
រឿង - ខ្ញុំងូតទឹក ហើយដុសធ្មេញ។
សកម្មភាព - គ្រូឱ្យសិស្សហិតក្លិន
ថ្នាំដុសធ្មេញ សម្ភារៈដែលត្រូវប្រើ -
ថ្នាំដុសធ្មេញ និងច្រាសដុសធ្មេញ
អត្ថបទរឿង - ខ្ញុំញ៉ាំអាហារពេលព្រឹក។
សកម្មភាព - គ្រូឱ្យសិស្សភ្លក់ឆៃប៉ូវ
ឬត្រីងៀត ... សម្ភារៈដែលត្រូវប្រើ -
ឆៃប៉ូវ ឬត្រីងៀត... អត្ថបទរឿង - ខ្ញុំ
ជួយមើលប្អូនស្រី។ សកម្មភាព - ឱ្យ
សិស្សលើករបស់អ្វីមួយមកដាក់លើ
ចង្កេះ ធ្វើដូចជាគេពប្អូន សម្ភារៈដែល
ត្រូវប្រើ -រូបតុក្កតា ឬខ្នើយ ឬវត្ថុអ្វី
ដែលធំស្រាលៗ អត្ថបទរឿង - ខ្ញុំពួ



សំឡេង «ក្រុកៗ»។ សកម្មភាព - គ្រូ
ឱ្យសិស្សស្តាប់សំឡេងពីក្នុងទូរស័ព្ទ ឬ
គ្រូអាចធ្វើសំឡេងដោយមាត់ ហើយឱ្យ
សិស្សធ្វើត្រាប់តាម សម្ភារៈដែលត្រូវ
ប្រើ - គ្មាន អត្ថបទរឿង - មើលចុះ!
ជ្រូកក៏ឃ្លានដែរ។ «អ៊ូក អ៊ូក អ៊ូក!»
សកម្មភាព - គ្រូឱ្យសិស្សធ្វើសំឡេង
ជ្រូកស្រែក និងបង្ហាញរូបជ្រូក សម្ភារៈ
ដែលត្រូវប្រើ - គ្មាន អត្ថបទរឿង -
អា! ដល់ពេលខ្ញុំលេងម្តងហើយ។
សកម្មភាព - គ្រូយកកូនឡានរុញ
លើដៃរបស់សិស្ស សម្ភារៈដែលត្រូវ
ប្រើ - កូនឡានជ័រ ឬកូនឡានឈើ ឬ
កូនឡានដែក គោលបំណងក្នុងការប្រើ



វិធីសាស្ត្រនេះ គឺដើម្បីឱ្យកុមារអាច
ចូលរួមស្ដាប់ការនិទានរឿងទៅតាម
កម្រិតសកម្មភាពផ្សេងៗគ្នារបស់
ពួកគេ។ សិស្សខ្លះអាចចូលរួមពិភាក្សា
អំពីគំនិតនៅក្នុងសាច់រឿង។ សិស្ស
ខ្លះទៀតអានរៀន នូវពាក្យថ្មីៗ និងរៀន
ពីការប្ដូរវេនគ្នាម្ដងម្នាក់ៗ។ ចំណែក
ឯសិស្សដទៃទៀត ជាពិសេស កុមារ
ខ្សោយសតិបញ្ញាធ្ងន់ធ្ងរ គឺដើម្បីឱ្យ
ពួកគេចេះបង្ហាញទឹកមុខ ឬកាយវិការ
អំពីវត្ថុដែលពួកគេចូលចិត្ត ឬមិនចូល
ចិត្ត។ សៀវភៅនេះអាចធ្វើឱ្យសិស្ស
ផ្សេងៗទៀត មានភាពសប្បាយរីករាយ
និងមានអន្តរសកម្មភាពជាមួយគ្នា ក្នុង



ការស្តាប់រឿងនិទាន និងធ្វើឱ្យសិស្ស
ទាំងនោះមានការចាប់អារម្មណ៍ជាមួយ
សៀវភៅ។



រឿងនេះបង្ហាញពីសកម្មភាពរបស់
កុមារាសុខនៅថ្ងៃអាទិត្យ ដែលជា
ថ្ងៃឈប់សម្រាកពីសាលារៀន។ សុខ
បានឃើញ ឮ ធុំក្លិន និងប៉ះពាល់វត្ថុ
ផ្សេងៗជាច្រើន តាមរយៈសកម្មភាព
របស់គេ តាំងពីភ្ញាក់ពីដំណេក លេង
ជាមួយប្អូនស្រី ដាក់ចំណីឱ្យសត្វ
មាន់ និងជ្រូក ព្រមទាំងលេងជាមួយ
មិត្តភក្តិ។ យើងអាចប្រើសៀវភៅ
នេះសម្រាប់ មត្តេយ្យសិក្សា និង
បឋមសិក្សា ឬអាចប្រើនៅផ្ទះក៏បាន។
យើងបង្កើតសៀវភៅនេះឡើង ដើម្បី
ឱ្យកុមារទាំងអស់អាចប្រើប្រាស់បាន
រួមទាំងកុមារខ្សោយសតិបញ្ញាផង



ដែរ។ គោលបំណងក្នុងការបង្កើត
សៀវភៅនេះឡើងគឺដើម្បីលើកកម្ពស់
នូវការចូលរួម និងការសិក្សារបស់កុមារ
តាមរយៈការធ្វើសកម្មភាពសប្បាយៗ
នៅអំឡុងពេលនៃការស្តាប់ និងអាន
រឿងនិទាន។

អត្ថបទរឿងដោយ/ Text by All Children Reading-Cambodia (a USAID funded project supporting the Ministry of Education, Youth and Sport) and partners រូបគំនូរដោយ សេង វិសុទ្ធ Illustration by Seng Visoth រចនាទំព័រដោយ អង្គការស៊ីប៉ា Design by Sipar This work is released under Creative Commons CC BY 4.0

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
ថ្ងៃអាទិត្យ, author: All Children Reading - Cambodia . illustrator: by Seng Visoth. Published by All Children Reading - Cambodia, © All Children Reading - Cambodia. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/